Note: When this publication was originally published, we were known as Protection & Advocacy, Inc. (PAI).
In October 2008, we changed our name from PAI to Disability Rights California.

Cambodian

# YIKES! កូនពិការរបស់ខ្ញុំ គេកំពុងតែយកមកពិនិត្យដើម្បីបណ្ដេញចេញ !

## តើខ្ញុំអាចធ្វើអ្វីបាន ?

## តើសិទ្ធិកូនរបស់ខ្ញុំមានអ្វីខ្លះ ?


**ABC Schools**
321 Apple Lane
Papyrus CA 98765
(123) 456-7890

ជូនមាតាបិតា

ខ្ញុំមានការសោកស្ដាយជំរាបមកដល់លោកអ្នកឲ្យបានជ្រាបថា ដោយយោងទៅលើអកប្បកិរិយាមិនគប្បីរបស់កូនលោកអ្នក កូនរបស់លោកអ្នកនឹងបណ្ដេញចេញពីសាលារៀន ABC នៅថ្ងៃស្អែកនេះហើយ ។

ហត្ថលេខា

Ms. Jones
នាយកសាលារៀន

**Protection & Advocacy, Inc.**
ទូរស័ព្ទមិនអស់លុយ 800.776.5746

| | |
|---|---|
| 100 Howe Ave., Suite 230-N<br>**Sacramento**, CA 95825<br>ទូរស័ព្ទ 916.488.9950 – ទូរសារ 916.488.9960<br>ប្រព័ន្ធ TTY 800.719.5798 | 1330 Broadway, Suite 500<br>**Oakland**, CA 94612<br>ទូរស័ព្ទ 510.267.1200 – ទូរសារ 510.267.1201<br>ប្រព័ន្ធ TTY 800.649.0154 |
| 3580 Wilshire Blvd., Suite #902<br>**Los Angeles**, CA 90010<br>ទូរស័ព្ទ 213.427.8747 – ទូរសារ 213.427.8767<br>ប្រព័ន្ធ TTY 800.727.4546 | 1111 Sixth Ave., Suite 200<br>**San Diego**, CA 92101<br>ទូរស័ព្ទ 619.239.7861 – ទូរសារ 619.239.7906<br>ប្រព័ន្ធ TTY 800.576.9269 |

ព្រឹត្តិប័ត្រ #5463.06 តុលា 2006

“Advancing the human and legal rights of people with disabilities.”

# **YIKES**! កូនពិការរបស់ខ្ញុំ គេកំពុងតែយកមកពិនិត្យដើម្បីបណ្តេញចេញ ! តើខ្ញុំអាចធ្វើអ្វីបាន ? តើសិទ្ធិកូនរបស់ខ្ញុំមានអ្វីខ្លះ ?

---

បើសិនជាកូនពិការរបស់លោកអ្នកគេកំពុងតែគិតបណ្តេញចេញពីសាលារៀនក្នុងតំបន់អប់រំ ("តំបន់") របស់វា, មានប្រការជាច្រើនដែលតំបន់អប់រំត្រូវអនុវត្តមុននឹងបណ្តេញក្មេងប្រុសស្រីចេញបាន ។ មិនតែប៉ុណ្ណោះ ច្បាប់អប់រំពិសេសរបស់រដ្ឋនិងរដ្ឋាភិបាលផ្តល់ឲ្យនូវសេចក្តីការពារខ្លះសំរាប់សិស្សដែលមានភាពពិការ ដែលគេកំពុងយកមកពិនិត្យគិត ដើម្បីបណ្តេញចេញនោះ ។

ព្រឹត្តិប័ត្រនេះនឹងផ្តល់ឲ្យនូវគោលពត៌មានខ្លះៗទាក់ទងទៅនិងសិទ្ធិរបស់កូនលោកអ្នក បើសិនជាក្មេងប្រុសស្រីនោះគេកំពុងតែយកមកពិនិត្យគិតដើម្បីបណ្តេញចេញ ហើយនិងបញ្ហាទាក់ទងផ្សេងៗទៀត ។

*អត្ថបទនៅក្នុងព្រឹត្តិប័ត្រនេះមាន :*

A. ការពិនិត្យឡើងវិញនូវការបណ្តេញចេញ និងកំណត់ជាក់ស្តែង
B. ការពិនិត្យឡើងវិញនូវការអំពាវនាវពីកំណត់ជាក់ស្តែង
C. សវនាការពីការបណ្តេញដោយក្រុមប្រឹក្សាអភិបាលសាលារៀន
D. ដាក់ពាក្យបណ្តឹងឧទ្ធរណ៍
E. ការបណ្តេញនៃកូនសិស្សដែលមិនទាន់មានសិទ្ធិទទួលការអប់រំពិសេស

*** បើសិនជាកូនរបស់លោកអ្នកបានទទួលការបញ្ឈប់បណ្តោះអាសន្នមិនឲ្យមករៀន ប៉ុន្តែគេមិនទាន់យកមកពិនិត្យគិតដើម្បីបណ្តេញចេញនូវឡើយ, សូមអានព្រឹត្តិប័ត្ររបស់យើងស្តី ពីការបញ្ឈប់បណ្តោះអាសន្នចំពោះក្មេងដែលមានសេចក្តីត្រូវការពិសេស, មានចំណងជើង EEK! កូនពិការរបស់ខ្ញុំ ឧស្សាទទួលការបញ្ឈប់បណ្តោះអាសន្នមិនឲ្យមករៀនញឹកញាប់ណាស់ ! ***

## A. *ការពិនិត្យមើលឡើងវិញនូវការបណ្តេញចេញ និងកំណាក់ជាត់ស្តែង*

ជាទូទៅ, នៅពេលណាតំបន់អប់រំសម្រេចបណ្តេញសិស្សទទួលការអប់រំពិសេស, តំបន់អប់រំត្រូវតែប្រជុំពិនិត្យមើលឡើងវិញនូវកំណាត់ជាក់ស្តែង**មិនហួសពី 10 ថ្ងៃ**[1]ក្រោយពីតំបន់អប់រំសម្រេចបណ្តេញចេញជាលើកដំបូង ។ គោលបំណងនៃការកំណាត់ពិនិត្យឡើងវិញនូវការជាក់ស្តែងដើម្បីពិនិត្យមើលបើអកប្បកិរិយាដែលនាំឲ្យមានការសម្រេចបណ្តេញចេញបានកើតឡើងដោយ ឬមកពី ហើយនិងមានទម្ងន់ទាក់ទងដល់ភាពពិការរបស់ក្មេងផ្ទាល់, ឬមកពីលិទ្ធផលផ្ទាល់នៃការអនុវត្តន៍ IEP មិនបានជោគជ័យរបស់សាលារៀន ។ ជួនកាល ការពិនិត្យឡើងវិញនូវកំណាត់ជាក់ស្តែង ក៏បានហៅថា ឬសំដៅហៅថា "កំណាត់ជាក់ស្តែង IEP" ឬ "IEP ពេលមានអាសន្នលើការបណ្តេញចេញ" ។

ការពិនិត្យឡើងវិញនូវកំណាត់ជាក់ស្តែងគឺបានធ្វើឡើងដោយក្រុម IEP, រួមមានមាតាបិតា និងបុគ្គលិកមានសិទ្ធិផ្សេងៗទៀត ។ ក្រុមពិនិត្យនេះត្រូវយកមកពិនិត្យគិតមើលនូវពត៌មានណាដែលទាក់ទងក្នុងសំណុំឯកសាររបស់សិស្ស, រួមសំណុំឯកសារ IEP, ការសំគាល់មើលគ្រូបង្រៀនណាមួយ, ហើយនិងពត៌មានទាក់ទងដែលបានផ្តល់ឲ្យដោយមាតាបិតា ។ [2] យោងទៅលើពត៌មាននេះ, ក្រុមពិនិត្យត្រូវតែយកមកពិនិត្យមើលនូវ :

1) ការធ្វើក្នុងចម្ងល់បានកើតឡើងដោយ ឬមកពី ហើយនិងមានទម្ងន់ទាក់ទងដល់ភាពពិការរបស់ក្មេងផ្ទាល់; ឬ
2) មកពីលិទ្ធផលផ្ទាល់នៃការធ្វើមិនបានជោគជ័យរបស់សាលារៀនក្នុងការអនុវត្តន៍ IEP ។

បើសិនជាករណី 1 ឬ 2 ខាងលើនេះជាការពិតចំពោះសិស្ស, ដូច្នេះសិស្សមិនអាចបណ្តេញចេញបានទេ ហើយការធ្វើក្នុងចម្ងល់ គឺបានយកមកពិនិត្យគិតពីការជាក់ស្តែងនៃភាពពិការរបស់សិស្ស ។ [3]

## បើសិនជាការធ្វើជាការជាក់ស្តែងនៃភាពពិការ

បើសិនជាការធ្វើនោះបង្ហាញឃើញថាជាការជាក់ស្តែងនៃភាពពិការ, ក្រុម IEP ត្រូវតែបំពេញការស្ទង់ប៉ាន់មើលនៃដំណើរអកប្បកិរិយា ហើយអនុវត្តធ្វើគំរោងអន្តរាគមន៍លើចរិយាមាយាទសំរាប់អោយសិស្ស ។ [4] បើសិនជាសិស្សមានគំរោងដូចនោះរួចទៅហើយ, ក្រុម IEP ត្រូវតែពិនិត្យឡើងវិញ ហើយធ្វើការកែសំរួលគំរោងចរិយាមាយាទជាការចាំបាច់ដើម្បីអធិប្បាយអំពីអកប្បកិរិយានោះ ។ [5] ដំណើរស្ទង់ប៉ាន់មើលលំអិតបានធ្វើឡើងក្រោមច្បាប់[6] California's Hughes Bill ប្រហែលជាអាចសមស្របទៅនិងតម្រូវការនៃការធ្វើដំណើរស្ទង់ប៉ាន់មើលអកប្បកិរិយាក្រោមច្បាប់រដ្ឋាភិបាលទាំងឡាយ ។ ក្រុម IEP ក៏ត្រូវតែដាក់ក្មេងនោះត្រឡប់មកទីកន្លែងបច្ចុប្បន្នរបស់គេវិញ លុះណាការធ្វើ ឬអកប្បកិរិយាមិនគប្បីនោះមានទាក់ទងនិងគ្រឿងអាវុធ, គ្រឿងញៀន ឬធ្វើឲ្យមានរបួសដល់ខ្លួនប្រាណលើអ្នកណាម្នាក់ធ្ងន់ធ្ងរ, ឬលុះត្រាណាមាតាបិតានិងសាលារៀនមានសេចក្តីយល់ព្រមគ្នា ។ [7]

បើសិនជាការធ្វើនោះបង្ហាញឃើញថាជាការជាក់ស្តែងនៃភាពពិការ, យោងទាំងស្រុង ឬមួយផ្នែកណាលើកម្មវត្ថុ 2 ខាងលើ - ការធ្វើក្នុងចម្ងល់គឺមានការទាក់ទងគ្នាផ្ទាល់ទៅនិងការធ្វើមិនបានជោគជ័យរបស់តំបន់អប់រំក្នុងការអនុវត្ត IEP, ដូច្នេះតំបន់អប់រំត្រូវតែប្រព្រឹត្តធ្វើការកែតម្រង់នៃការទន់ខ្សោយ ឬបញ្ហា ។ [8]

## បើសិនជាការធ្វើនោះមិនមែនជាការជាក់ស្តែងនៃភាពពិការទេ

បើសិនជាក្រុម IEP ពិនិត្យគិតថា អកប្បកិរិយា**មិន**មែនជាការជាក់ស្តែងនៃភាពពិការទេ, ដូច្នេះតំបន់អប់រំប្រហែលជាអាចបន្តធ្វើទម្រង់ការបណ្តេញចេញ ហើយប្រហែលជានឹងអាចធ្វើអនុសាសដល់ក្រុមប្រឹក្សាអភិបាលតំបន់បណ្តេញសិស្សនោះចេញ ។ នៅពេលណាក្រុម IEP ពិនិត្យគិតថា អកប្បកិរិយាមិនមែនជាការជាក់ស្តែងនៃភាពពិការ, ក្រុមនេះនិយាយថា (1) អកប្បកិរិយាមិនមែនបានធ្វើឡើងដោយ, ឬថាអកប្បកិរិយាមិន

បានដាក់ទម្ងន់ទាក់ទងទៅលើភាពពិការរបស់សិស្សទេ, ហើយ/ឬ (2) អកប្បកិរិយាមិនមែនជាលិទ្ធផលផ្ទាល់នៃការធ្វើមិនបានជោគជ័យរបស់តំបន់អប់រំក្នុងការអនុវត្ត IEP របស់សិស្សឡើយ ។

បើសិនជាកូនរបស់លោកអ្នកបានទទួលការបញ្ឈប់បណ្តោះអាសន្ន ឬដកចេញចំនួន 10 ថ្ងៃជាប់ៗគ្នា, ហើយនៅពេល ឬនៅក្រោយពេលដកចេញ តំបន់អប់រំសម្រេចចង់ធ្វើអនុសាសបណ្តេញក្មេងប្រុសស្រីនោះចេញ, កូនលោកអ្នកមានសិទ្ធិវិលត្រឡប់ទៅទីកន្លែងរៀនសូត្រដែលអកប្បកិរិយាមិនគប្បីបានកើតឡើងវិញបាន (ក្រោយពីបានទទួលការបញ្ឈប់បណ្តោះអាសន្ន 10 ថ្ងៃជាប់ៗគ្នា ឬការដកចេញនោះបានចប់) រង់ចាំការពិនិត្យមើលឡើងវិញនូវកំណត់ជាក់ស្តែង ។ ការលើកលែង គឺបើសិនចរិយា ឬអកប្បកិរិយាក្មេងរួមមានអាវុធ, គ្រឿងញៀន ឬការធ្វើឲ្យមានរបួសដល់ខ្លួនប្រាណធ្ងន់ធ្ងរ, នៅក្នុងករណីណាមួយ សាលារៀនអាចផ្លាស់ប្តូរទីកន្លែងសិក្សាបាន 45 ថ្ងៃទៅដាក់ទីកន្លែងផ្សេងទៀត ។ [៩] ក៏ប៉ុន្តែ ការផ្លាស់ប្តូរ ឬការដកចេញដែលរាប់បញ្ចូលទៅច្រើនជាង 10 ថ្ងៃជាប់ៗគ្នានៅក្នុងឆ្នាំសិក្សា, រួមទាំងការបណ្តេញ, កូនលោកអ្នកត្រូវតែបានទទួលការសិក្សាសាធារណៈសមរម្យមិនគិតថ្លៃ (FAPE) សូម្បីតែកូនលោកអ្នកសិក្សានៅទីកន្លែងជំនួស ក៏ដោយ ។ កម្មវិធី FAPE តម្រូវមានន័យថា តំបន់អប់រំត្រូវតែផ្តល់កិច្ច បំរើទាំងឡាយ, ដល់សេចក្តីចាំបាច់, ដើម្បីទុកពេលវេលាឲ្យសិស្សរីកចំរើនក្នុងការរៀនសូត្រសមរម្យតាមគំរោងសិក្សាទូទៅ ហើយនិងដើម្បីកើនចំរើនឲ្យបានសម្រេចតាមគោលបំណង IEP របស់គេបាន ។ [10]

ឧទាហរណ៍, ឧបមាថាកូនលោកអ្នកបានទទួលពិន័យរួចហើយក្នុងរយៈពេល 10 ថ្ងៃជាប់ៗគ្នាលើការបញ្ឈប់បណ្តោះចំពោះអកប្បកិរិយាមិនគប្បីរីកសាយឡើង ហើយនៅថ្ងៃទី 10 នៃ ការបញ្ឈប់ដកចេញបណ្តោះអាសន្ន, តំបន់អប់រំបានផ្តល់ដំណឹងនេះមកប្រាប់លោកអ្នកថា កូនលោកអ្នកគេកំពុងតែពិនិត្យគិតបណ្តេញចេញដោយសារតែអកប្បកិរិយាមិនគប្បីរីកកាន់តែធំឡើង ។ តំបន់អប់រំឥឡូវនេះមានចំនួនតែ 10 ថ្ងៃ ដើម្បីជំនុំពិនិត្យឡើងវិញនូវកំណត់ជាក់ស្តែងជាមួយលោកអ្នក ហើយនិងសមាជិកដែលទាក់ទងនៃក្រុម IEP ។ ចំពោះ ឧទាហរណ៍នៃគោលបំណងនេះ, សន្មតថាអកប្បកិរិយាមិនគប្បីរីករាលដាលមិន

បានធ្វើឲ្យប៉ះពាល់រូបសដល់ខ្លួនប្រាណធ្ងន់ធ្ងរ ហើយក៏មិនមានទាក់ទងជាមួយគ្រឿងញៀន និងគ្រឿងអាវុធ, ដែលមានន័យថា នៅពេលកំពុងរងចាំការប្រជុំពិនិត្យឡើងវិញនូវកំណត់ជាក់ស្តែង ហើយនៅក្នុងរយៈពេលទម្រង់កំណត់ជាក់ស្តែងនោះ, កូនលោកអ្នកអាចនៅសិក្សាក្នុងទីកន្លែងសិក្សាវាធម្មតាបាន ។ នៅក្នុងពេលប្រជុំពិនិត្យនូវកំណត់ជាក់ស្តែង, បើសិនជាក្រុម IEP រកឃើញថា អកប្បកិរិយាមិនគប្បីរីករាលដាលរបស់កូនលោកអ្នកជាការទាក់ទងផ្ទាល់ដល់ ហើយ/ឬក៏កើតឡើងដោយសារភាពពិការរបស់វា, តំបន់អប់រំមិនអាចបណ្តេញក្មេងចេញបានឡើយ ។ ម្យ៉ាងទៀត តំបន់អប់រំត្រូវតែធ្វើដំណើរស្ទង់ប៉ាន់មើលអកប្បកិរិយា ហើយបង្កើតគំរោងទប់រារាំងនូវការរីកធំឡើងនៃអកប្បកិរិយាមិនគប្បីសំរាប់ឲ្យកូនលោកអ្នក បើសិនជាកូនលោកអ្នកមិនទាន់បានធ្វើដំណើរស្ទង់ប៉ាន់មើលអកប្បកិរិយា ហើយនិងគំរោងទប់រារាំងអកប្បកិរិយាមិនគប្បីនៅឡើយ ។ សូម្បីកូនលោកអ្នកមានគំរោងអកប្បកិរិយារួមហើយក៏ដោយ, បន្ទាប់មកក្រុម IEP ត្រូវតែពិនិត្យមើលវាឡើងវិញ ហើយកែតម្រូវគំរោងនោះបើវាចាំបាច់ដើម្បីអធិប្បាយពីការរីកដុះដាលធំឡើងនៃអកប្បកិរិយាមិនគប្បីដែលនាំឲ្យខ្លួនធ្លាក់ក្នុងការបំរុងបណ្តេញចេញ ។ [11]

នៅក្នុងឧទាហរណ៍ខាងលើ បើសិនអកប្បកិរិយាមិនគប្បីដែលរីកធំឡើងនោះក៏ធ្វើឲ្យរបួសគ្រោះថ្នាក់ដល់ខ្លួនប្រាណក្មេងដទៃទៀត, តំបន់អប់រំប្រហែលជាអាចដាក់ក្មេងនោះនៅទីកន្លែងជំនួសរបបូតបានដល់ 45 ថ្ងៃសិក្សា, ជាទីកន្លែងកូនលោកអ្នកនៅសិក្សារបបូត និងក្រោយទម្រង់កំណត់ជាក់ស្តែង លុះណាចៅក្រម ឬមន្ត្រីសវនាការបញ្ចេញបទបញ្ជា ។ បើសិនជាកូនលោកអ្នកបានទទួលការបញ្ឈប់បណ្តោះអាសន្ន 3 ថ្ងៃមុន ដោយមានរឿងផ្សេងនៅក្នុងឆ្នាំសិក្សាដដែលនេះ, បន្ទាប់មកនៅថ្ងៃទី 8 នៃថ្ងៃទី 10 ដែលបានបញ្ឈប់បណ្តោះអាសន្នពីអកប្បកិរិយាមិនគប្បីជាប់ៗគ្នានៅក្នុងឧទាហរណ៍នេះ, តំបន់អប់រំត្រូវតែផ្តល់ឲ្យកូនលោកអ្នកនូវកម្មវិធី FAPE ។ កម្មវិធី FAPE ត្រូវតែបានផ្តល់ឲ្យក្នុងរយៈពេលបញ្ឈប់បណ្តោះអាសន្នទាំងមូល ហើយទាំង 45 ថ្ងៃសិក្សានៅទីកន្លែងសិក្សាជំនួសនោះ ។

## B. *ការពិនិត្យឡើងវិញនូវកំណត់ដាក់ស្តែងតាមទម្រង់សវនាការត្រឹមត្រូវរួសរាន់*

បើសិនជាតំបន់អប់រំគិតឃើញថាការចោទដែលគ្មានភស្តុតាងពីអកប្បកិរិយាដែលនាំឲ្យមានការសម្រេចរបស់តំបន់អប់រំបណ្តេញកូនលោកអ្នកចេញ គឺ**មិន**មែនជាការដាក់ស្តែងនៃភាពពិការរបស់ក្មេង ហើយសម្រេចកែផ្លាស់ប្តូរទីកន្លែងដាក់កូនលោកអ្នក, តំបន់អប់រំត្រូវតែផ្តល់លោកអ្នកនូវលិខិតបញ្ជាក់ពីការសម្រេចរបស់គេ ។ តំបន់អប់រំក៏ត្រូវតែផ្តល់ឲ្យលោកអ្នកនូវលិខិតអំពីទម្រង់ការពារនិងសិទ្ធិផងដែរ ។ [12]

បើសិនជាលោកអ្នកមិនយល់ស្របទៅនិងកំណត់ការរបស់តំបន់អប់រំទេ, លោកអ្នកមានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ានិងសេចក្តីសម្រេចតាមទម្រង់ការសវនាការអប់រំពិសេសត្រឹមត្រូវរួសរាន់បាន ។ នៅពេលទម្រង់ការសវនាការត្រឹមត្រូវរួសរាន់, មន្ត្រីសវនាការមិនលំអៀងធ្វើការពិនិត្យមើលឡើងវិញនូវចរិយាកូនលោកអ្នកបានបង្កើតឡើងដោយ, ឬមានការទាក់ទងផ្ទាល់និងទំនាក់ទំនងដ៏ធ្ងន់ដល់, ភាពពិការរបស់ក្មេង ឬក៏ចរិយានោះជាលិទ្ធផលទទួលមកផ្ទាល់ពីការអនុវត្តន៍ IEP មិនបានជោគជ័យរបស់តំបន់អប់រំ ។ សវនាការរួសរាន់ គឺត្រូវកើតមានឡើងក្នុងកំឡុងពេល 20 ថ្ងៃសិក្សានៃការស្នើសុំឲ្យមានសវនាការ ហើយលោកអ្នកគួរតែទទួលលិទ្ធផលនៃការសម្រេចចុងក្រោយពីមន្ត្រីសវនាការក្នុងកំឡុងពេល 10 ថ្ងៃសិក្សា ក្រោយពីសវនាការបានបញ្ចប់ ។ [13] នៅក្នុងកំឡុងពេល 7 ថ្ងៃ ក្រោយពីការស្នើសុំឲ្យមានសវនាការរួសរាន់បានដាក់ពាក្យ, ច្បាប់តម្រូវឲ្យសាលារៀននិងមាតាបិតាជួបជំនុំគ្នាដើម្បីដោះស្រាយបញ្ហាបណ្តឹងនោះ, លុះណាតែភាគីទាំងពីរគឺមាតាបិតានិងសាលារៀនយល់ព្រមជាលាយលក្ខណ៍អក្សរមិនព្រមធ្វើដូច្នេះ ។ [14]

បើសិនជាលោកអ្នកដាក់ពាក្យសុំឲ្យមានទម្រង់ការសវនាការរួសរាន់ ពីព្រោះតែលោកអ្នកមិនយល់ស្របជាមួយកំណត់ដាក់ស្តែង ហើយ/ឬជាមួយការផ្លាស់ប្តូរទីកន្លែង ហើយកូនលោកអ្នកបានបញ្ជូនទៅដាក់នៅទីកន្លែងជំនួសបណ្តោះអាសន្ន, កូនលោកអ្នកប្រហែលជាអាចនៅទីកន្លែងជំនួសបណ្តោះអាសន្នពេញមួយរយៈពេលនៃទម្រង់សវនាការ ។ បើសិនជារយៈពេលដាក់នៅទីកន្លែងជំនួសនោះដល់ពេលបញ្ចប់មុនពេលបញ្ចប់សវនាការ,

បន្ទាប់កូនលោកអ្នកគួរតែត្រឡប់ទៅទីកន្លែងសិក្សាធម្មតារបស់វាវិញ លុះត្រាតែលោកអ្នក និងតំបន់អប់រំយល់ព្រមធ្វើដូច្នេះ ។ យ៉ាងណាមិញ បើសិនជាតំបន់អប់រំមិនបានបញ្ជូនកូនលោកអ្នកទៅដាក់ទីកន្លែងសិក្សាជំនួសបណ្តោះអាសន្នជាផ្នែកនៃការព្រមានប្រដៅនោះទេ, ដូច្នេះកូនរបស់លោកអ្នកប្រហែលជាអាចនៅសិក្សានៅទីកន្លែងធម្មតារបស់វាក្នុងរយៈពេលទម្រង់សវនាការនោះ ។ [15]

លោកអ្នកនឹងត្រូវការដាក់ពាក្យសំរាប់ទម្រង់សវនាការត្រឹមត្រូវឲ្យបានឆាប់រហ័ស *មុនថ្ងៃខែឆ្នាំបានដាក់សំរាប់ឲ្យតំបន់អប់រំធ្វើសវនាការបណ្តេញចេញជាមួយក្រុមប្រឹក្សាអភិបាលតំបន់អប់រំ* ("ក្រុមប្រឹក្សា") ។ មូលហេតុដែលលោកអ្នកចង់ដាក់ពាក្យសំរាប់ទម្រង់សវនាការត្រឹមត្រូវ មុនពេលលោកអ្នកត្រូវមកបង្ហាញខ្លួនមុនក្រុមប្រឹក្សា គឺពីព្រោះលោកអ្នកចង់ស្នើសុំមន្ត្រីសវនាការនូវបទបញ្ជាដែលឲ្យតំបន់អប់រំឈប់ដំណើរសវនាការបណ្តេញចេញនោះ នៅពេលលោកអ្នកកំពុងតែស្វែងរកទម្រង់សវនាការត្រឹមត្រូវរួសរាន់របស់លោកអ្នក, ហើយមន្ត្រីសវនាការត្រូវការពេលវេលាដើម្បីគិតគូរពីការស្នើសុំនោះ ហើយនិងបញ្ចេញបទបញ្ជាដល់តំបន់អប់រំឲ្យពន្យាពេលសវនាការបណ្តេញចេញ រហូតដល់ក្រោយពេលទម្រង់សវនាការត្រឹមត្រូវចប់សិន ហើយសេចក្តីសម្រេចបានបញ្ចេញផងដែរ ។ បើសិនជាថ្ងៃខែឲ្យមកបង្ហាញខ្លួនមុនពេលក្រុមប្រឹក្សាបានដាក់រួចមកហើយ, លោកអ្នកនៅតែអាចដាក់ពាក្យសំរាប់ទម្រង់សវនាការត្រឹមត្រូវរួសរាន់ក្រោយពេលបង្ហាញខ្លួន ក៏ប៉ុន្តែជាថ្មីម្តងទៀតលោកអ្នកនឹងត្រូវប្រព្រឹត្តបែបបទនេះឲ្យបានរួសរាន់ដែលធ្វើទៅបាន ។ ពត៌មានបន្ថែមអំពីទម្រង់សវនាការត្រឹមត្រូវ និងការបណ្តេញចេញអាចរកមាននៅក្នុងផ្នែក 6 និង 8 នៃក្បួនរបស់ភ្នាក់ងារ PAI *ស្តីពីសិទ្ធិអប់រំពិសេសនិងបន្ទុក (Special Education Rights and Responsibilities, SERR)* ។ [16]

លទ្ធផលនៃទម្រង់សវនាការត្រឹមត្រូវ, មន្ត្រីសវនាការអាចបញ្ជាឲ្យមានការផ្លាស់ប្តូរក្នុងទីកន្លែងសិក្សារបស់សិស្ស ។ មន្ត្រីសវនាការប្រហែលជាអាចរកឃើញថា អកប្បកិរិយាជាការជាក់ស្តែងនៃភាពពិការរបស់ក្មេង ហើយបញ្ជាឲ្យសាលារៀនទទួលយកក្មេងនោះដាក់នៅទីកន្លែងសិក្សាដើមវិញ ។ ចំពោះសិស្សទាំងឡាយដែលបានដកចេញពីទីកន្លែងសិក្សាមុនដោយមន្ត្រីសាលារៀន ពីព្រោះតែអកប្បកិរិយាមិនគប្បីទាក់ទងនិងគ្រឿងអាវុធ, គ្រឿង

ញៀន ឬធ្វើឲ្យមានរបួសដល់ខ្លួនប្រាណធ្ងន់ធ្ងរ ឬពីព្រោះតែតំបន់អប់រំបានរកឃើញពី អកប្បកិរិយាមិន មែនជាការជាក់ស្តែងដល់ភាពពិការរបស់ក្មេង, មន្ត្រីសវនាការប្រហែល ជាអាចយល់ឃើញថា អកប្បកិរិយាមិនមែនជាគ្រឿងអាវុធ, គ្រឿងញៀន ឬជាទោស កម្មដល់ការរបួសខ្លួនប្រាណធ្ងន់ធ្ងរ ហើយបញ្ជាឲ្យដាក់សិស្សមកសិក្សានៅទីកន្លែងដែល មន្ត្រីសាលារៀនប្រដេញសិស្សចេញវិញ ។ [17]

ជាឧទាហរណ៍, ឧបមាថាកូនស្រីរបស់លោកអ្នក ដែលរៀននៅក្នុងការអប់រំពិសេស, បានគ្រវែងស្លាបប៉ាកកាក៏ប៉ះត្រូវគ្រូបង្រៀន ។ តំបន់អប់រំមានជំហរថា ការប្រព្រឹត្តបែប នេះជាការប្រហារទាក់ទងទៅនិងគ្រឿងអាវុធ, ដកកូនស្រីលោកអ្នកចេញទៅដាក់ទីកន្លែង សិក្សាជំនួស, ហើយនៅពេលពិនិត្យឡើងវិញនូវកំណត់ជាក់ស្តែង, តំបន់អប់រំពិនិត្យគិតថា ការប្រព្រឹត្តនៃគ្រវែងចោលខ្មៅដៃមិនមែនជាការជាក់ស្តែងនៃភាពពិការរបស់កូនស្រី លោកអ្នកទេ ។ លោកអ្នកមិនយល់ស្រប ។ លោកអ្នកជឿថា (1) ស្លាបប៉ាកកាមិនមែន ជាគ្រឿងអាវុធ, (2) អំពើនៃការគ្រវែងស្លាបប៉ាកកាជាអំពើទាក់ទងផ្ទាល់ទៅនិងភាពពិការ របស់កូនស្រីលោកអ្នក ហើយ (3) អំពើនៃការគ្រវែងស្លាបប៉ាកកាជាលទ្ធផលផ្ទាល់មកពី ការអនុវត្តន៍មិនបានជោគជ័យលើគំរោងអកប្បកិរិយារបស់កូនស្រីលោកអ្នក និង IEP របស់ តំបន់អប់រំតែម្តង ។ ពីព្រោះតែលោកអ្នកមិនយល់ស្រប, លោកអ្នកដាក់ពាក្យសុំឲ្យមាន ទម្រង់សវនាការត្រឹមត្រូវរួសរាន់ ។ នៅពេលសវនាការ, បើសិនជាមន្ត្រីសវនាការពិនិត្យ គិតឃើញថា ស្លាបប៉ាកកាគឺមិនមែនជាគ្រឿងអាវុធ ហើយអំពើដែលនាងប្រព្រឹត្តធ្វើនោះមក ពីការទាក់ទងផ្ទាល់ដល់ភាពពិការរបស់នាង, មន្ត្រីសវនាការប្រហែលជាអាចបញ្ជាឲ្យតំបន់ អប់រំយកកូនស្រីលោកអ្នកមកដាក់ទីកន្លែងសិក្សារបស់វាធម្មតាវិញ ហើយបញ្ឈប់ដំណើរ ការរបស់តំបន់អប់រំបណ្តេញកូនស្រីលោកអ្នក ។ ម្យ៉ាងវិញទៀត បើសិនជាមន្ត្រីសវនាការ ក៏បានពិនិត្យគិតថា គំរោងអកប្បកិរិយាមិនបានអនុវត្តតាមត្រឹមត្រូវទេ, មន្ត្រីសវនាការ ប្រហែលជាអាចបញ្ជាឲ្យក្រុម IEP ជួបជំនុំនិងកែតម្រូវគំរោងអកប្បកិរិយានោះ ។

នៅក្នុងស្ថានភាពដែលសិស្សទាំងឡាយសិក្សាក្នុងទីកន្លែងដើមរបស់គេនៅឡើយ ពីព្រោះតែអកប្បកិរិយាមិនគប្បីមិនមានចូលរួមគ្រឿងអាវុធ, គ្រឿងញៀន ឬធ្វើឲ្យរបួសដល់ ខ្លួនប្រាណធ្ងន់ធ្ងរ (ឬពីព្រោះក្រុម IEP បានពិនិត្យគិតឃើញថា អកប្បកិរិយាជាការជាក់ស្តែង

នៃភាពពិការរបស់ក្មេង), មន្ត្រីសវនាការនៅតែអាចបញ្ជាឲ្យមានការផ្លាស់ប្តូរទីកន្លែងសិក្សារបស់សិស្សទៅដាក់នៅទីកន្លែងបណ្តោះអាសន្នបានដល់ទៅ 45 ថ្ងៃសិក្សា បើសិនជាមន្ត្រីសវនាការរកឃើញថា ការថែទាំទីកន្លែងសិក្សរបស់សិស្សបច្ចុប្បន្ន គឺទំនងមានទម្ងន់ដល់លទ្ធផលក្នុងការធ្វើឲ្យគ្រោះថ្នាក់ដល់សិស្ស ឬអ្នកដទៃ, សូម្បីតែអកប្បកិរិយាមិនគប្បីជាការជាក់ស្តែងនៃភាពពិការរបស់សិស្សក៏ដោយ ។ នៅក្នុងរយៈពេល 45 ថ្ងៃសិក្សា, បើសិនជាគ្មានសេចក្តីសម្រេចបានធ្វើឡើងអំពីប្រភេទទីកន្លែងអចិន្ត្រៃយ៍ដាក់សិស្សនោះទេ, សាលារៀនអាចស្នើសុំឲ្យមានសវនាការមួយទៀត ដើម្បីស្នើសុំបទបញ្ជាពីមន្ត្រីសវនាការដើម្បីដាក់សិស្សនៅក្នុងទីកន្លែងបណ្តោះអាសន្នសំរាប់ 45 ថ្ងៃសិក្សាបន្ថែមទៀត ។ [18]

បើសិនជាលោកអ្នកមិនបានទទួលជោគជ័យ និងមិនសប្បាយចិត្តទៅនិងសេចក្តីសម្រេចរបស់មន្ត្រីសវនាការក្នុងទម្រង់សវនាការត្រឹមត្រូវរួសរាន់ទេ, លោកអ្នកមានសិទ្ធិនិងជម្រើសសំរាប់បណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចនោះបាន ។ [19]

## *C. សវនាការពីការបណ្តេញដោយក្រុមប្រឹក្សាអភិបាលសាលារៀន*

បើសិនជាតំបន់អប់រំសម្រេចធ្វើអនុសាសបណ្តេញចេញ, តំបន់អប់រំនឹងបញ្ជូនលោកអ្នក ហើយនិងកូនលោកអ្នកទៅក្រុមប្រឹក្សាអភិបាលតំបន់អប់រំ ("ក្រុមប្រឹក្សា") ដើម្បីធ្វើសវនាការពិនិត្យគិតមើលកូនប្រុសស្រីរបស់លោកអ្នកគួរតែបណ្តេញចេញឬទេ ។ សវនាការជាមួយក្រុមប្រឹក្សានេះ គឺចាត់ធ្វើក្នុងកំឡុងពេល 30 ថ្ងៃសិក្សា[20] ក្រោយពេលនាយកសាលារៀនសម្រេចបណ្តេញកូនលោកអ្នកចេញ, ហើយតម្រូវឲ្យក្រុមប្រឹក្សាធ្វើសេចក្តីសម្រេចក្នុងកំឡុងពេល 10 ថ្ងៃសិក្សា ក្រោយពីសវនាការក្រុមប្រឹក្សាមក លុះត្រាណាលោកអ្នកស្នើសុំឲ្យមានការពន្យាពេលសវនាការ ឬសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ។ [21] សូមគត់សំគាល់ថាសវនាការនេះគឺវាខុសប្លែកពីសវនាការទម្រង់ការដែលបានអធិប្បាយក្នុង Section B (ផ្នែក B) ខាងលើ ។

បើសិនជាលោកអ្នកមិនបានទទួលជោគជ័យក្នុងទម្រង់សវនាការត្រឹមត្រូវរួសរាន់ហើយក្រុមប្រឹក្សាក៏បានធ្វើអនុសាសហើយសម្រេចបណ្តេញកូនលោកអ្នកចេញ, លោក

អ្នកមានសិទ្ធិនិងជម្រើសដាក់ពាក្យបណ្ដឹងដល់សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាបាន ។ លោកអ្នក មានចំនួន 30 ថ្ងៃក្រោយពីក្រុមប្រឹក្សាបានធ្វើសេចក្ដីសម្រេចដើម្បីដាក់ពាក្យប្ដឹងដល់ក្រុមប្រឹក្សាអប់រំខោនធី (County Board of Education) ។ [22]

មានច្បាប់ទម្លាប់ជាច្រើនទាក់ទងទៅនិងអនុសាសន៍សំរាប់ការបណ្ដេញចេញ ហើយនិងការដាក់ឲ្យចូលមកវិញក្រោយពីបានបណ្ដេញចេញ, ហើយច្បាប់ទាំងឡាយនេះ*មានច្រើនប្រភេទ*ពីតំបន់អប់រំមួយទៅតំបន់អប់រំមួយផ្សេងទៀត ។ លោកអ្នកគួរតែទាក់ទងមកតំបន់អប់រំកូនរបស់លោកអ្នកសំរាប់ស្នើសុំច្បាប់ទម្លាប់ចម្លងជាលាយលក្ខណ៍អក្សរ ។ ពត៌មានបន្ថែមអំពីច្បាប់ទាំងឡាយអាចរកអាននៅក្នុង Cal. Ed. Code (ខូដអប់រំរដ្ឋកាលីហ្វ័រនីញ៉ា) §§ 48916–48927 ។

### *D. ដាក់ពាក្យបណ្ដឹងឧទ្ធរណ៍*

សូមទូន្មានថា មានថ្ងៃកំណត់សំខាន់សំរាប់ការដាក់ពាក្យប្ដឹងតវ៉ាដែលទាក់ទងទៅនិងបណ្ដឹងឧទ្ធរណ៍នៃការកំណត់ជាក់ស្ដែងនិងទម្រង់ការបណ្ដេញចេញរបស់តំបន់ ។ យើងក៏សូមទូន្មានលោកអ្នកឲ្យស្វែងរកការផ្ដល់ឱវាទពីច្បាប់បន្ថែមទៀតអំពីថ្ងៃកំណត់ទាំងឡាយឲ្យបានឆាប់រហ័ស ។ បើសិនជាលោកអ្នកមានបំណងចង់រកជំនួយជួយបន្ថែម ឬអ្នកធ្វើជាតំណាង, លោកអ្នកគួរតែទាក់ទងមក Office of Administrative Hearings (OAH) (ការិយាល័យសវនាការក្នុងក្របខ័ណ្ឌរដ្ឋបាល) ហើយស្នើសុំបញ្ជីបញ្ជូនមេធាវី ហើយ/ឬ អ្នកគាំទ្រដែលមានជំនាញពិសេសក្នុងការការពារសិទ្ធិក្នុងការអប់រំ ។ ពត៌មានទាក់ទងមានដូចតទៅ :

Office of Administrative Hearings
Special Education Division
2349 Gateway Oaks Drive, Suite 200
Sacramento, CA 95833-4231
ទូរស័ព្ទ : 916-263-0880
ទូរសារ : 916-263-0890

លោកអ្នកអាចរកស្នើសុំក្រដាសសំរាប់ផ្សះផ្សានិងសវនាការនៅលើទំព័រអប់រំពិសេសក្នុងគេហទំព័ររបស់ OAH ។ [23] ចាប់ពីខែតុលា ឆ្នាំ 2006, ក្រដាសបំពេញទាំងឡាយនោះមានជាភាសាអង់គ្លេស និងស្ពែនីស ។ នៅតាមគេហទំព័រ, ការិយាល័យ OAH ក៏បានបង្កើតឲ្យមានអត្ថបទសិទ្ធិមាតាបិតានិងទម្រង់ការពារ (Parents' Rights and Procedural Safeguards) ជាភាសាអង់គ្លេស, ស្ពែនីស, ពីលីពីន, ម៉ុង និងភាសាវៀតណាម ។ បើសិនជាលោកអ្នកមិនមាន អ៊ិនធើណិត ទេ, លោកអ្នកអាចទូរស័ព្ទមកការិយាល័យ OAH ផ្ទាល់ ហើយស្នើសុំឯកសារចម្លងទាំងឡាយនោះបាន ឬលោកអ្នកអាចទូរស័ព្ទទៅការិយាល័យក្នុងតំបន់លោកអ្នករស់នៅ ។

## *E. ការបណ្តេញនៃកូនសិស្សដែលមិនទាន់មានសិទ្ធិទទួលការអប់រំពិសេស*

បើសិនជាតំបន់អប់រំមិនទាន់បានធ្វើការស្ទង់ប៉ាន់មើលកូនរបស់លោកអ្នកសំរាប់ការអប់រំពិសេសនៅឡើយ, ហើយលោកអ្នកមានអារម្មណ៍ថាកូនលោកអ្នកមានសិទ្ធិទទួលការអប់រំពិសេស, កូនរបស់លោកអ្នកមានសិទ្ធិស្មើទៅនិងការការពារមុនបណ្តេញចេញដែលសិស្សទទួលការអប់រំពិសេសមាន **បើសិន**ជាលោកអ្នកអាចបង្កើតឯកសារថាតំបន់អប់រំបានយល់ដឹងថាកូនរបស់លោកអ្នកមានភាពពិការ ***មុន***និងអកប្បកិរិយារបស់ក្មេងប្រព្រឹត្តធ្វើមិនគប្បីដែលនាំឲ្យមានការប្រមានណែនាំ ។ តំបន់អប់រំគឺបានយល់ថាមានការយល់ដឹងពីភាពពិការរបស់កូនលោកអ្នកមុនពេលក្មេងនោះមានអកប្បកិរិយាមិនគប្បី មុនពេលវាមានអកប្បកិរិយាមិនគប្បី, មានប្រការមួយនៃប្រការទាំងបួនដូចតទៅជាការពិត[24] :

1) លោកអ្នកបញ្ចេញការព្រួយបារម្ភ, ជាលាយលក្ខណ៍អក្សរ, ដល់គ្រូបង្រៀន ឬ មន្ត្រីសាលារៀនផ្សេងទៀត, ថាក្មេងត្រូវការសេចក្តីត្រូវការអប់រំពិសេស (ការលើកលែងគឺធ្វើឡើង បើសិនជាមាតាបិតាមិនចេះអក្សរ ឬមានភាពពិការដែលរារាំងមាតាបិតាបញ្ចេញបង្ហាញការព្រួយបារម្ភឲ្យគេដឹងឮជាលាយលក្ខណ៍អក្សរបាន),
2) លោកអ្នកបានស្នើសុំឲ្យគេធ្វើការពិនិត្យឲ្យតម្លៃសំរាប់ការអប់រំពិសេស, ឬ

3) គ្រូបង្រៀន ឬបុគ្គលិកសាលាផ្សេងៗទៀតបានបញ្ចេញការព្រួយបារម្ភអំពីអកប្បកិរិយាក្មេង ឬការសម្ដែងដល់មន្ត្រីអប់រំពិសេស ឬបុគ្គលិកគ្រប់គ្រងនៅក្នុងតំបន់អប់រំសាលារៀនទាំងមូល ។

បើសិនជាលោកអ្នកមានអារម្មណ៍ថា តំបន់អប់រំបានយល់ដឹងនៃភាពពិការរបស់លោកអ្នក មុននឹងពេលតំបន់អប់រំសម្រេចបណ្ដេញកូនលោកអ្នកចេញ, លោកអ្នកមានសិទ្ធិហើយនិងជម្រើសដល់ការដាក់ពាក្យបណ្ដឹងទម្រង់ការសវនាការត្រឹមត្រូវដើម្បីបង្ហាញនូវការជំទាស់របស់លោកអ្នក ។ លោកអ្នកគួរតែស្នើសុំឲ្យមានសវនាការរួសរាន់ ហើយដាក់ពាក្យបណ្ដឹងឲ្យបានឆាប់រហ័ស ហើយដាក់ភ្ជាប់អ្វីៗ និងភស្ដុតាងជាលាយលក្ខណ៍អក្សរនៃប្រការមួយ ឬច្រើនជាងមួយនៃប្រការបួនបានចុះខាងលើដែលទាក់ទងទៅនិងការយល់ដឹងមុនរបស់សាលារៀន ។

បើសិនជាតំបន់អប់រំមិនបានយល់ដឹងអ្វីអំពីភាពពិការរបស់លោកអ្នកមុនទេ ដូច្នេះកូនលោកអ្នកប្រហែលជាអាចទទួលការពិន័យ ដូចជាក្មេងផ្សេងៗទៀតដែរ,[25] ហើយប្រហែលជាមិនអាចទទួលការពិនិត្យមួយកំរិតបន្ថែមទៀតដែលអធិប្បាយនៅក្នុងប្រព្រឹត្តិប័ត្រនេះ ។

បើសិនជាលោកអ្នកធ្វើការស្នើសុំសំរាប់ការពិនិត្យវាយតម្លៃសំរាប់សិទ្ធិទទួលការអប់រំពិសេសក្នុងកំឡុងពេលកូនលោកអ្នកកំពុងទទួលពិន័យ, ដូច្នេះការពិនិត្យវាយតម្លៃត្រូវតែធ្វើឡើងឲ្យបានរួសរាន់ ។ មិនតែប៉ុណ្ណោះ ច្បាប់តម្រូវឲ្យមានការពិនិត្យវាយតម្លៃរួសរាន់, គ្មានច្បាប់ទម្លាប់ដាក់កំរិតលើពេលវេលាទេ ដែលការពិនិត្យវាយតម្លៃរួសរាន់ត្រូវតែបញ្ចប់បានពេញលេញ ។ នៅពេលពិនិត្យវាយតម្លៃកំពុងតែមានដំណើរការ កូនលោកអ្នកប្រហែលជាអាចនៅទីកន្លែងជំនួសសំរាប់ការបញ្ឈប់បណ្ដោះអាសន្ន ឬការបណ្ដេញចេញ, ដោយគ្មានកិច្ចបំរើអប់រំ ។ បើសិនជាការពិនិត្យវាយតម្លៃពិនិត្យមើលថា កូនរបស់លោកអ្នកមានភាពពិការ ហើយមានសិទ្ធិទទួលការកិច្ចបំរើអប់រំពិសេសបាន, បន្ទាប់មកតំបន់អប់រំត្រូវតែផ្ដល់ឲ្យកូនលោកអ្នកនូវកិច្ចបំរើអប់រំពិសេសទាំងអស់ ហើយច្បាប់និងបន្ទុកសំរាប់ការអប់រំពិសេសទាំងអស់ ។ [26]

***សំគាល់ :*** *បើសិនជាលោកអ្នកចង់បានផ្នែកផ្សេងៗទៀតពីក្បួន SERR ឬព្រឹត្តិប័ត្រផ្សេងៗទៀត, លោកអ្នកទាញយកពីគេហទំព័រ PAI តាមអាសយដ្ឋាន www.pai-ca.org ឬលោកអ្នកស្នើសុំបានដោយទូរស័ព្ទមកការិយាល័យរបស់យើងដោយមិនអស់លុយលេខ (800) 776-5746*

## អក្សរកាត់ឯលក់កន្លែងច្បាប់

| | |
|---|---|
| §, §§ | ផ្នែក, ផ្នែកច្រើន |
| 20 U.S.C. | ចំណងជើង 20 ខូដនៃសហរដ្ឋអាមេរិក (United States Code) |
| 34 C.F.R. | ចំណងជើង 34 ខូដនៃច្បាប់សហពន្ធ (Code of Federal Regulations) |
| Cal. Ed. Code | ខូដអប់រំរដ្ឋកាលីហ្វ័រនីញ៉ា (California Code of Regulations) |
| 5 C.C.R. | ចំណងជើង 5 ខូដនៃច្បាប់រដ្ឋកាលីហ្វ័រនីញ៉ា (California Code of Regulations) |

# កត់សំគាល់ខាងចុង

[1] 20 U.S.C. §§ 1415(k)(1)(E); 34 C.F.R. § 300.530(e)(1)

[2] 20 U.S.C. §§ 1415(k)(1)(E)(i); 34 C.F.R. § 300.530(e)(1)

[3] 20 U.S.C. §§ 1415(k)(1)(E), 1415(k)(1)(F); 34 C.F.R. § 300.530(e)(1)(i) & (ii)

[4] 20 U.S.C. § 1415(k)(1)(F)(i); 34 C.F.R. § 300.530(f)(1)(i)

[5] 20 U.S.C. § 1415(k)(1)(F)(ii); 34 C.F.R. § 300.530(f)(1)(ii)

[6] Cal. Ed. Code §§ 56520 – 56525; 5 C.C.R. §§ 3001 (d), (e) និង (f), និង 3052; *ចូរមើល* ផ្នែក 5 នៃក្បួនរបស់ភ្នាក់ងារ PAI, *សិទ្ធិអប់រំពិសេសនិងបន្ទុក (Special Education Rights and Responsibilities)*

[7] 20 U.S.C. § 1415(k)(1)(F)(iii), 1415(k)(1)(G); 34 C.F.R. § 300.530(f)(2), 300.530(g)

[8] 34 C.F.R. § 300.530(e)(3)

[9] 20 U.S.C. §§ 1415(j) និង (k)(7); 34 C.F.R. §§ 300.530(f)(2), 300.530(g)

[10] 34 C.F.R. §§ 300.530(b)(2) និង (d), 300.536

[11] 20 U.S.C. § 1415(k)(1)(F); 34 C.F.R. § 300.530(f)

[12] 20 U.S.C. § 1415(k)(1)(H); 34 C.F.R. § 300.530(h)

[13] 20 U.S.C. §§ 1415(k)(3)(A) និង (B), 1415(k)(4)(B); 34 C.F.R. § 300.532(c)(1) និង (2)

[14] 34 C.F.R. § 300.532(c)(3)

[15] 20 U.S.C. §§ 1415(k)(4)(A); 34 C.F.R. § 300.533

[16] *ក្បួនសិទ្ធិអប់រំពិសេសនិងបន្ទុក (Special Education Rights and Responsibilities)* មានចែកជូនច្រើនភាសាសំរាប់ទាញយកដោយមិនគិតថ្លៃតាមគេហទំព័រកុំព្យូទ័រតាម www.pai-ca.org/pubs … ដោយទូរស័ព្ទមកលេខ 800.776.5746

[17] 20 U.S.C. §§ 1415(k)(2) និង (3)(B); 34 C.F.R. § 300.532(b)

[18] 34 C.F.R. § 300.532(b)(3)

[19] 20 U.S.C. §§ 1415(g) និង (i); 34 C.F.R. §§ 300.514, 300.516; Cal. Ed. Code §56505(k)

[20] តារាងពេលវេលាសំរាប់ធ្វើសវនាការមុនក្រុមប្រឹក្សាអភិបាល គឺ 40 ថ្ងៃ, បើក្រុមប្រឹក្សាអភិបាលមិនជួបពិភាក្សាជារៀងរាល់អាទិត្យទេ ។

[21] Cal. Ed. Code § 48918(a)

[22] Cal. Ed. Code § 48919

[23] www.oah.dgs.ca.gov/Special+Education/Default.htm

[24] 20 U.S.C. §1415(k)(5); 34 C.F.R. §§ 300.534(a) and (b)

[25] 20 U.S.C. §1415(5)(D)(i); 34 C.F.R. §§ 300.534(d)(1)

[26] 20 U.S.C. §1415(5)(D)(ii); 34 C.F.R. §§ 300.534(d)(2)